សាលាឧទ្ធរណ៍
រឿងព្រហ្មទណ្ឌ
ខ :៨០៦
៣-០៩-២០១៣
រាលដីកា
៧៤ក្រIV "វ"
៨-០៨-២០១៤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-០៧-២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤ ដោយមាន ៖

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

**ក្រឡាបញ្ជី**

លោក [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ : ៨០៦ ចុះថ្ងៃទី០៣-០៩-២០១៣ ដែលមាន ៖

១-ជនជាប់ចោទឈ្មោះ [redacted] ផាន ភេទប្រុស អាយុ៦០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរគ្រូពេទ្យ ទីកន្លែងកំណើត និងសព្វថ្ងៃភូមិ[redacted]ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] "រ" មានកូន០៤នាក់ កម្រិតវប្បធម៌ថ្នាក់ទីបញ្ចប់ ទោសពីមុនគ្មាន (នៅក្រៅឃុំ) ។

-មានលោក [redacted] សោភ័ណ ជាមេធាវីការពារសិទ្ធិ ។

២-ជនជាប់ចោទឈ្មោះ[redacted] ចាន់ថន ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបើកបររថយន្ត ទីកន្លែងកំណើត និងសព្វថ្ងៃនៅភូមិ[redacted] ឪពុកឈ្មោះ

[redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០៥នាក់ ទោសពីមុនគ្មាន (នៅក្រៅឃុំ) ។

ជាប់ចោទពីបទ: បើកបរបង្កឱ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃដោយអចេតនា ប្រព្រឹត្តនៅភូមិខ្លាគ្រហឹម ឃុំតាអោម ស្រុកត្រាំកក់ ខេត្តកំពង់ចាម កាលពីថ្ងៃទី២១-០៧-២០១២ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្ដន្ទាទោសតាមមាត្រា៦៩ និងមាត្រា៧០ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ។

- ១-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៥៣ឆ្នាំ មុខរបរជាជាងជួសជុលរថយន្ត មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។

-ទាមទារសំណងចំនួន ៥.២០០ (ប្រាំពាន់ពីររយ) ដុល្លាអាមេរិក និងប្រាក់ជម្ងឺចិត្តចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ។

6200$
8000

២-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ៤០ឆ្នាំ មុខរបរជាអាជីវកម្ម ទីលំនៅ [redacted] ។

-ទាមទារសំណងចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លាអាមេរិក ។

## ឯរឿងហេតុមានដូចតទៅ ៖

កាលពីថ្ងៃទី៣១-០៧-២០១២ វេលាម៉ោងដប់ប្រាំមួយសែសិបនាទី ស្ថិតនៅផ្លូវលេខ ៣ចន្លោះគីឡូម៉ែត្រលេខ ៧៣-៧៤ ក្នុងភូមិខ្លាគ្រហឹម ឃុំតាអោម ស្រុកត្រាំកក់ ខេត្តតាកែវ មានករណីគ្រោះថ្នាក់ចរាចរណ៍កើតឡើងបង្កដោយរថយន្តម៉ាក HINO ពណ៌ខៀវ-ស ពាក់ស្លាកលេខភ្នំពេញ ៣A-៣៣៥០ បើកបរដោយឈ្មោះ [redacted] ចាន់ថន ភេទប្រុស អាយុ៣៨ឆ្នាំ ធ្វើដំណើរទិសដៅពីជើងទៅត្បូង លុះដល់ចំណុចកើតហេតុ បានប៉ះជាមួយរថយន្តម៉ាក TOYOTA CAMRY ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ ២L-៨១៥១ បើកបរដោយឈ្មោះ [redacted] ផាន ភេទប្រុស អាយុ៦០ឆ្នាំ ធ្វើដំណើរទិសដៅពីត្បូងទៅជើង បណ្ដាលឱ្យខូចខាតធ្ងន់ធ្ងរ ព្រមទាំងកិនបែកប្រអប់លេខរថយន្តធំ ០១ គ្រឿង ។ រីឯរថយន្តបង្កហេតុម៉ាក HINO និងរថយន្តម៉ាកTOYOTA CAMRY មានការខូចខាតធ្ងន់ធ្ងរដែរ ។ ក្រោយពីវាស់វែងតាមជំនាញ សមត្ថកិច្ចនគរបាលចរាចរណ៍សន្និដ្ឋានថា កំហុសបណ្ដាលមកពីអ្នកបើកបរ ឈ្មោះ [redacted] ចាន់ថន និងឈ្មោះ [redacted] ផាន បើកបរក្នុងល្បឿនធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្នទើបបណ្ដាលឱ្យគ្រោះថ្នាក់កើតឡើង ។

រឿងនេះត្រូវបានសាលាដំបូងខេត្តតាកែវ បានវិនិច្ឆ័យសេចក្ដីតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ: ២២ "ក" ចុះថ្ងៃទី០៤-០៧-២០១៣ ដែលមានខ្លឹមសារសម្រេចសេចក្ដីដូចខាងក្រោម៖

១.ឱ្យឈ្មោះ [redacted] ផាន , ឈ្មោះ [redacted] ចាន់ថន និងឈ្មោះ [redacted] សេងហួរ រួមគ្នាសងសំណងជាប្រាក់ទៅ ដើមបណ្ដឹងរដ្ឋប្បវេណី ៖

៤៣១

-ឈ្មោះ [redacted] ភ៉ាវុធ ចំនួន ៥.២០០ ដុល្លារអាមេរិក (ប្រាំពាន់ពីរដុល្លារ) ។

-ឈ្មោះ [redacted] ផល្លា ចំនួន ៨.០០០ ដុល្លាអាមេរិក (ប្រាំបីពាន់ដុល្លា) ។

ការទាមទារលើសពីនេះលើកចោល ។ តាមបញ្ញត្តិមាត្រា៦៩ និងមាត្រា៧០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

២.វត្ថុតាងមាន៖ ប្រអប់លេខរថយន្តធំចំនួន ០១ , មីលីតាំងចំនួន ០១ ,ខ្មៅយឡាកាមចំនួន ០១ ,កូនជ្រុកចំនួន ០១ ,កាទែប្រេងម៉ាស៊ីនចំនួន ០១ សម្រេចប្រគល់ឱ្យឈ្មោះ [redacted] សំបូរ ជាម្ចាស់កម្មសិទ្ធិវិញ ។

សាលក្រមនេះ ប្រកាសជាសាធារណៈនៅថ្ងៃទី០៤-០៧-២០១៣ កំបាំងមុខឈ្មោះ [redacted] ផាន , [redacted] ចាន់ថន និងឈ្មោះ [redacted] សេងហ៊ួរ តែចាត់ទុកចំពោះមុខ បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី២៧-១២-២០១៤ ។

បានឃើញ សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី០២-០៤-២០១៤ ។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿងក្តី

-ឈ្មោះ [redacted] ផាន បានទទួលដំណឹងពីថ្ងៃសវនាការនេះតាមរយៈមេធាវី ។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ផាន នៅចៅក្រមស៊ើបសួរ៖ នៅថ្ងៃទី២១-០៧-២០១២ វេលាម៉ោងប្រហែលប្រាំ ខ្លួនបានចេញពីទីរួមខេត្តតាកែវ ឆ្ពោះទៅផ្ទះខ្លួនស្ថិតនៅភូមិខ្នាចខាងត្បូង ដល់ចំនុចខាងជើងផ្សារអង្គតាសោម ប្រហែលប្រាំមួយរយម៉ែត្រ ក៏មានឡានធំមួយបើកពីជើងត្បូងក្នុងល្បឿនយ៉ាងលឿន ហើយបានវេចង្កូតមកប៉ះនឹងឡានរបស់ខ្លួនចំកង់មុខខាងឆ្វេងនៃឡានរបស់ខ្លួន ធ្វើឱ្យឡានរបស់ខ្លួនវេចង្កូតរេទៅផ្លូវម្ខាងទៀត ។ ពេលដែលឡានធំមកប៉ះឡានខ្លួន គឺឡានខ្លួននៅចំណែកខាងស្តាំនៃចំណែកផ្លូវរបស់ខ្លួន ដល់ពេលឡានខ្លួនឈប់នៅចំចំណែកខាងស្តាំនៃផ្លូវម្ខាងទៀត ហើយសមត្ថកិច្ចមកវាស់វែង គឺមិនមែនមកវាស់វែង នៅកន្លែងដែលឡានខ្លួនឈប់ ពេលនោះខ្លួនតវ៉ា ក្នុងការវាស់វែងនេះដែរ តែខាងសមត្ថកិច្ចឆ្លើយថា វាស់វែង តែកន្លែងឡានឈប់ ។ នៅក្នុងរឿងនេះ ខ្លួនក៏ជាជនរងគ្រោះដែរ ហើយខ្លួនសុំប្តឹងទាមទារសំណងការខូចខាត និងជម្ងឺចំនួន ៣.០០០ (បីពាន់) ដុល្លាអាមេរិក ពីឈ្មោះ [redacted] សេងហួរ និងអ្នកបើកបរឈ្មោះ [redacted] ចាន់ថន ។ ឡានរបស់ខ្លួនបានជួសជុលអស់ប្រាក់ចំនួន ១.៩៤០ (មួយពាន់ប្រាំបួនរយសែសិប) ដុល្លាអាមេរិក ។

- អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ចាន់ថន នៅសាលាដំបូងខេត្តតាកែវ៖ ខ្លួនបានបើកបរជាច្រើនឆ្នាំមកហើយ មានប័ណ្ណបើកបរត្រឹមត្រូវ ។ នៅថ្ងៃកើតហេតុខ្លួនបើកបររថយន្តម៉ាក HINO ពីភ្នំពេញទៅខេត្តកំពត ហើយរថយន្តម៉ាក HINO មានប្រព័ន្ធភ្លើង និងបានត្រួតពិនិត្យ

ពីមន្ទីរសាធារណៈការត្រឹមត្រូវ ។ ពេលនោះខ្លួនបើកបរក្នុងល្បឿន ៣០ គីឡូម៉ែត្រ ទៅ៤០ គីឡូម៉ែត្រ ក្នុងមួយម៉ោងប៉ុណ្ណោះ ។ លុះដល់ចំណុចកើតហេតុមានរថយន្តតូរីស ០១ គ្រឿង បើកមកពីត្បូង រួចមានរថយន្តម៉ាក TOYOTA CAMARY មកពីត្បូងដែរ បើកវ៉ារថយន្តតូរីស ចូលមកចំណែកផ្លូវពីមុខរថយន្តគេចប៉ះកង់រថយន្តខ្លួនពីចំហៀងខាងឆ្វេង បណ្តាលឱ្យដាច់យ៉ី កាច់ចង្កូតមិនកើត ជាន់ហ្វ្រាំងមិនស៊ី វេចង្កូតទៅបុករថយន្តពីរគ្រឿងទៀតក្នុងយានដ្ឋានតែម្តង ។ ប៉ុន្តែរថយន្តនៅក្នុងយានដ្ឋានទាំងពីរគ្រឿងនោះខូចខាតយ៉ាងណានោះ ខ្លួនមិនបានដឹងទេ ព្រោះភ្លាមៗនោះខ្លួនបានរត់តែម្តង ខ្លាចគេវាយ តែខាងក្រុមហ៊ុនចូលទៅដោះស្រាយ ។ រថយន្តម៉ាក TOYOTA CAMARY បើកវ៉ារថយន្តសាំយ៉ុង ចូលមកចំណែកផ្លូវខ្លួនចំពីមុខតែម្តងធ្វើឱ្យខ្លួនមិនអាចគេចផុតឡើយ ។ ចម្ងាយពីរថយន្តខ្លួន ទៅរថយន្ត TOYOTA CAMRY ប្រហែលប្រាំ ទៅប្រាំមួយម៉ែត្រពីគ្នាប៉ុណ្ណោះ ទើបខ្លួនមិនអាចឈប់រថយន្តទាន់បានទេ ។

-ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខ្លួនមិនបានឃើញហេតុការណ៍ទេ គ្រាន់តែដឹងថាឡានហើណូ បើកលឿន ខ្លួនប្តឹងទាមទារសំណងពីក្រុមហ៊ុនប៉ាស៊ីហ្វិក ខ្លួនមិនបានប្តឹងទាមទារ ពីឈ្មោះ [redacted] ផាន ទេ ។ ខ្លួនទាមទារចំនួន ៨.០០០ ដុល្លារ ហើយតុលាការបានប្រគល់ឱ្យ ៤.០០០ដុល្លាអាមេរិកហើយ ។

-ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វុធ ខ្លួនបានទទួលសំណងលុយចំនួន ១.០០០ ដុល្លាអាមេរិក ខ្លួនប្តឹងទាមទារពីក្រុមហ៊ុនប៉ាស៊ីហ្វិក ។ ខ្លួនមិនបានប្តឹងទាមទារ ពីឈ្មោះ [redacted] ផាន ទេ ។

-អានចម្លើយសាក្សីឈ្មោះ [redacted] សាង ពេលកើតហេតុ ខ្លួនអង្គុយនៅខាងមុខផ្ទះខាងលិចផ្លូវ ឃើញរថយន្តធំមួយ បើកមកពីទិសខាងជើង បុកលីស្សូរផាំង រួចខ្លួនចេញទៅមើល ឃើញរថយន្តធំបើកចេញពីថ្នល់ជាតិទៅខាងកើតថ្នល់ ចូលទៅបុករថយន្តពីរគ្រឿងទៀតគេទុកនៅមុខផ្ទះ ។

- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ៖ កូនក្តីខ្លួនប្តឹងមកដោយមានមូលហេតុ២ ទី១ គឺប៉ះពាល់ដល់សិទ្ធិ និងទី២ គឺប៉ះពាល់ផលប្រយោជន៍ ។ ការសម្រេចរបស់សាលាដំបូងខេត្តតាកែវ ប៉ះពាល់ដល់សិទ្ធិកូនក្តីខ្លួនខ្លាំងណាស់ កូនក្តីខ្លួនក៏ជាជនរងគ្រោះដែរ ។ បើពិនិត្យមើលគំនូសផ្លូវ គំនូសរូបភាព ចម្លើយរបស់កូនក្តីខ្លួនមានភាពដូចគ្នា ជាសត្យានុម័ត ។

-មហាអយ្យការលើកឡើងថា៖ បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទធ្វើឡើងត្រឹមត្រូវតាមច្បាប់ ។ រឿងនេះកើតឡើងដោយសាររថយន្តពីរ ។ ករណីនេះ ជូនក្រុមប្រឹក្សាពិចារណាតាមផ្លូវច្បាប់ ។

- មេធាវីធ្វើការសន្និដ្ឋាន៖ ការចោទប្រកាន់នេះប៉ះពាល់ទី១ ក្នុងរឿងនេះកូនក្តីខ្លួនក៏ជាជនរងគ្រោះដែរ ។ វាជារឿងព្រហ្មទណ្ឌ តែសាលាដំបូងមិនបានសម្រេចពីទោសព្រហ្មទណ្ឌ ដូច្នេះបើគ្មានទោស គឺគ្មានសំណងនោះទេ ។ ខ្លួនស្នើសុំក្រុមប្រឹក្សាសម្រេចបដិសេធសាលក្រមរបស់តុលាការខេត្តតាកែវ និងសម្រេចអំពីសំណងដែលកូនក្តីខ្លួនបានស្នើសុំ ។

- ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ៖ ប្តឹងទាមទារប្រាក់ចំនួន ៨.០០០ ដុល្លាអាមេរិក ។

- ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ៖ ប្តឹងទាមទារប្រាក់ចំនួន ៥.២០០ ដុល្លាអាមេរិក ។

- ក្រោយពីបានស្តាប់អំណាចចម្លើយរបស់ជនជាប់ចោទ[redacted]ផាន
- ក្រោយពីបានស្តាប់អំណាចចម្លើយរបស់ជនជាប់ចោទ [redacted] ចាន់ថន
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានពិចារណាលើគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

យល់ឃើញថា

១- ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] ផាន ប្តឹងនឹងសាលក្រមព្រហ្មទណ្ឌលេខ: ២២ “ក” ចុះថ្ងៃទី០៤-០៧-២០១៣ របស់សាលាដំបូងខេត្តតាកែវ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើករឿងនេះ ដើម្បីជំនុំជម្រះដោយយោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- ក្រុមប្រឹក្សាយល់ថា ៖ ក្នុងរឿងនេះពិតជាមានការបើកបរដោយឡានម៉ាក TOYOTA CAMRY ហើយជ្រុលចង្កូតទៅបុកឡានម៉ាក HINO រួចឡាន HINO ក៏ជ្រុលទៅបុក ឡានម៉ាក LEXUS RX 300 និងឡានម៉ាកNISSAN PATROL មែនយោងតាមគំនូសស្នាមគ្រោះថ្នាក់ចុះថ្ងៃទី២១-០៧-២០១២ (ឯកសារលេខ.១) ។ ជនជាប់ចោទទាំងពីរ បានបើកបរក្នុងល្បឿនលឿនដែលជាហេតុនាំឱ្យ ជនជាប់ចោទទាំងពីរមិនអាចគេចពីគ្រោះថ្នាក់បាន ។ ជនជាប់ចោទទាំងពីរបានបំពាន កាតព្វកិច្ចប្រុងប្រយ័ត្ន និងកាតព្វកិច្ចព្យាករណ៍ទុកជាមុន និងបញ្ចៀសគ្រោះថ្នាក់ យោងតាមមាត្រា ៩ កថាខណ្ឌទី២ ,មាត្រា ៦៩ និង មាត្រា ៧០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

៣- តំណាងមហាអយ្យការសន្និដ្ឋានថា៖ បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទធ្វើឡើងត្រឹមត្រូវតាមច្បាប់ ។ រឿងនេះកើតឡើងដោយសាររថយន្តពីរ ។ ករណីនេះ តំណាងមហាអយ្យការទុកជូនក្រុមប្រឹក្សាពិចារណាតាមផ្លូវច្បាប់ គប្បីក្រុមប្រឹក្សាពិចារណា ។

៤- ក្រុមប្រឹក្សាយល់ឃើញថា ៖ សាលាដំបូងខេត្តតាកែវសម្រេចមិនត្រូវនឹងគតិច្បាប់ ត្រង់ថាសាលាដំបូងមិនទាន់បានសម្រេចអំពីកំហុស ឬពិរុទ្ធភាពផ្នែកព្រហ្មទណ្ឌទេ ប៉ុន្តែបានសម្រេចអំពីសំណងការខូចខាតទៅវិញ ។ ក្នុងករណីនេះ សាលាដំបូងគប្បីសម្រេចពីពិរុទ្ធភាពជាមុនសិន ទើបឈានដល់សម្រេចអំពីសំណងការខូចខាត ឬជម្ងឺចិត្ត ។ ឈ្មោះ [redacted] ចាន់ថន និងស៊ុន សេងហួរ មិនបានប្តឹងឧទ្ធរណ៍ ដូច្នេះ ក្រុមប្រឹក្សាមិនពិចារណានោះទេ ។/

៥- តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភ៌វុធ និងឈ្មោះ [redacted] ផល្លា បានឆ្លើយថា ពួកខ្លួនមិនបានប្ដឹងទាមទារសំណងការខូចខាតពីឈ្មោះ [redacted] ផាន នោះទេ ។ ពួកខ្លួនសុំសំណងការខូចខាតពី ក្រុមហ៊ុនប៉ាស៊ីហ្វិក ដូច្នេះគប្បីក្រុមប្រឹក្សាពិចារណា លុបចោលសេចក្ដីសម្រេចសាលាដំបូងដែលឱ្យឈ្មោះ [redacted] ផាន សងសំណងទៅដើមបណ្ដឹងរដ្ឋប្បវេណី ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] ផាន ប្ដឹងនឹងសាលក្រមព្រហ្មទណ្ឌលេខ: ២២ "ក" ចុះថ្ងៃទី០៤-០៧-២០១៣ របស់សាលាដំបូងខេត្តតាកែវ ទុកត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ២២ "ក" ចុះថ្ងៃទី០៤-០៧-២០១៣ របស់សាលាដំបូងខេត្តតាកែវ លើកលែងតែ ត្រង់ចំណុចទី១ នៃសេចក្ដីសម្រេច "បង្គាប់ឱ្យឈ្មោះ [redacted] ផាន ,ឈ្មោះ [redacted] ចាន់ថន និងឈ្មោះ [redacted] សេងហួរ រួមគ្នាសងសំណងជាប្រាក់ ទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំនួន ៥.២០០ (ប្រាំពាន់ពីររយ) ដុល្លាអាមេរិក និងឈ្មោះ [redacted] ចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លាអាមេរិក" ត្រូវកែប្រែមកជា "បង្គាប់ឱ្យឈ្មោះ [redacted] ចាន់ថន និងឈ្មោះ [redacted] សេងហួរ រួមគ្នាសងសំណងជាប្រាក់ ទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំនួន ៥.២០០ (ប្រាំពាន់ពីររយ) ដុល្លាអាមេរិក និងឈ្មោះ [redacted] ចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លាអាមេរិក" ។

-ចំណុចក្រៅពីនេះ រក្សាទុកនៅដដែល ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨-០៨-២០១៤ កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ ចំពោះមុខមេធាវីការពារសិទ្ធិជនជាប់ចោទ ។

ទុកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។/.

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០១៤
ក្រឡាបញ្ជី
[redacted]

៤៣៧៥